សេចក្ដីស្រមៃ ផ្អែមល្ហែមក៏គង់អាចរំភើបចិត្តធ្វើឱ្យបេះដូងកើតក្ដីកក់ក្ដៅភ្លាមៗបានមែន នេះជាសុភមង្គល ដ៏ធំក្នុងជីវិតមនុស្សរាល់គ្នា។ ប៉ុន្តែវិលមកវិញ វាបានត្រឹមតែមួយប៉ប្រិចភ្នែក ប៉ុណ្ណោះ ព្រោះគ្រប់យ៉ាងវាមិនអាចកើតឡើងបានទេ។

មិនយូរប៉ុន្មានយើងនឹងបែកគ្នា កូននាគអើយ! យើងនឹងវិលទៅតាមទីតាំងប្រភពដើមរៀងៗគ្នា ។ នាងនឹងភ្លេចបងកម្មករម្នាក់នេះ ដូចដែលយើង ក៏មានកាតព្វកិច្ច និងវិបត្តិជាច្រើនទៀតដែលត្រូវផ្ចង់ចិត្តដោះស្រាយ។

«បងឯងនៅស្ងៀម? គេងលក់?»

ដៃនាយឈោងមកក្រសោបចង្កេះនាងភ្លាម ធ្វើឱ្យតូចស្រីផ្អើលសឹងរបូតម៉ូតូដួលធ្លាក់ផ្លូវរទេះទាំងអស់គ្នា។

បរិយាកាសរឹតតែស្ងាត់។ គេដឹងថានាងចង់ឱ្យគេដកដៃចេញ តែចិត្តគេនៅតែពន្យារតាមបញ្ជាបេះដូង។ រយៈពេលម្ភៃម៉ោងមកនេះ គេភ្លាត់មកឆ្ងាយ ជួបអ្នកណាក៏អត់ នៅជិតដិតនឹងស្រីតូចតែម្នាក់។

ពេលវេលាដដែល អ្នកត្រៀមនឹងចាកចេញទៅ ហេតុអីចិត្តនៅបង្កប់ក្ដីស្រណោះស្មើនឹងមនុស្សមាននិស្ស័យជាមួយគ្នារយជាតិមកហើយ?

គេនិយាយតិចៗដោយផ្ទឹបមុខទៅលើសក់នាងហើយខ្សឹបដាក់ត្រចៀកនាង៖

«ថ្ងៃក្រោយ! ឈប់ទៅនៅឆ្ងាយរបៀបនេះទៅ! ផ្ទះអនាគតនោះ វាឆ្ងាយ វាជ្រៅពេកហើយ! ខ្លួនធំហើយត្រូវនៅក្រោមការគ្រប់គ្រងរបស់ឪពុកម្ដាយ!»

«ខ្ញុំអត់មានពុកម៉ែទេ!»

នាងទំនងជាស្ថិតក្នុងអារម្មណ៍ជិតស្និទ្ធនឹងកក់ក្ដៅដូចគ្នាបានជាមិនខឹងពេលត្រូវគេឱបពីក្រោយហើយចាប់ផ្ដើមសារភាពស្ថានភាពគ្រួសារ។ ដៃនាយស្រយុត។

អារម្មណ៍ជាក្មេងកំព្រាដែលត្រូវឪពុកម្ដាយបោះបង់ចោលនៅកណ្ដាលប្រទេសមហាអំណាច ព្រោះញៀនល្បែងគ្មានលទ្ធភាពចិញ្ចឹម ជាអារម្មណ៍ដែលយល់ថាគ្មានអ្នកណាដូចខ្លួនទេនៅលើលោកនេះ ស្រាប់តែពេលនេះមកជួបមនុស្សម្នាក់ដែលនិយាយពីរឿងកំព្រើកំព្រាចេញមកបានដោយអារម្មណ៍ធម្មតាគ្មានខ្វល់ខ្វាយអ្វី?

តទៅនាងរស់ដោយរបៀបនេះរហូតឬអ្វីកូននាគព្រាត់មេឃ?

តាមថានាយត្រូវរបូតដៃចេញ តែបែរជាម្ដងណេះ ឱបនាងណែនជាងមុន។

«ខ្ញុំជាក្មេងមណ្ឌល! ខ្ញុំធំឡើងក៏ចេញមកហើយត្រៀមរៀបចំមណ្ឌលខ្លួនឯង! ខ្ញុំមានពុកម្ដាយដែលរើសយកមកចិញ្ចឹម ដីព្រៃនោះជាមរតកគាត់ផ្ទេរឱ្យខ្ញុំ ខ្ញុំទុកកសាងជាសាលារៀនសម្រាប់ក្មេងៗកូនអ្នករស់នៅក្នុងព្រៃ! ពួកវាមិនអាចទៅរៀននៅសាលាឆ្ងាយៗបានទេ!»

នេះឬសេចក្ដីប្រាថ្នារបស់នាង?

«ប្រវត្តិគ្រួសារខ្លួនឯងនៅឯណា! ចាំបងជួយរកឱ្យ!»

«មិនដឹង! អ្នកស្រុកថាខ្ញុំប្រហែលជាកូនអ្នកភ្នំពេញដែលគេយកមកផ្ដុងចោល! ចាស់ៗតំណាល យប់មួយមានឡានមួយបោលលឿនណាស់ គេឈប់បន្តិចហើយក៏ចេញទៅ! មិនបានប៉ុន្មានអ្នកស្រុកឮសូរទារកយំ ក្មេងនោះគឺខ្ញុំហ្នឹងហើយ! ចាស់ៗថាខ្ញុំមកដល់ទីនេះ ខ្ញុំឈឺសល់តែស្បែក ប្រហែលមកពីខ្ញុំឈឺ បានជាគ្រួសារនោះគេមិនចង់ចំណាយពេលមកមើលខ្ញុំ! ចាស់ស្រុកម្ដុំនេះយកខ្ញុំទៅលើភ្នំឱ្យគ្រូបុរាណមើលថែទាំ ខ្ញុំក៏បានរស់នៅទីនោះបន្តជីវិត សុំទឹកដោះម្នាក់នេះផង ម្នាក់នោះផង គ្រាន់នឹងជៅ! អាយុបាន៨ឆ្នាំល្មមឱ្យខ្ញុំចាំឱសថបុរាណទាំងអស់បានខ្ទេច! ពេលនេះខ្ញុំមានអីមិនល្អ! ចាំបាច់អីត្រូវការគ្រួសារមួយដែលគេមិនត្រូវការខ្ញុំ!»

បុរសកាន់តែឱបនាងណែន ព្រោះសេចក្ដីអាណិតស្រលាញ់។

**បេះដូងនេះ ស្រែករកអូន**

ចាប់ផ្ដើមថ្ងៃថ្មី បុរសបើកភ្នែកមកវិញភ្លាមៗជាមួយអារម្មណ៍ថ្មីដែលដឹងថាលោកនេះ មានអ្នកណាម្នាក់កំពុងយកចិត្តទុកដាក់ដល់ខ្លួនគេកម្រិតប៉ុណ្ណា។

តាមរយៈការរំឭកពីយប់មិញរបស់មនុស្សជំនិត គេចាប់ផ្ដើមមានអារម្មណ៍ថាស្រឡាញ់និងពេញចិត្តជីវិតមួយនេះឡើងវិញសន្សឹមៗ។

នរៈសង្ហាច្រត់ដៃក្រោកចេញពីគ្រែតម្រង់មករកទ្វារកញ្ចក់ ចំពេលព្រះអាទិត្យរះក្រហមថ្លែលំអពាសដែនពសុធា ។ ទ្រនិចនាឡិកាលើតុ លោតចំលេខ១២ គឺថ្ងៃត្រង់ខ្ពស់ទៅហើយ។ គេដើរក្រេសៗ

ជាមួយអាវដំណេក មានកែវទឹកមួយមកជាមួយ សំដៅរានហាលរវេភ្នែកពាសពេញសួនបុប្ផាខាងក្រោមផ្ទះ។

បេះដូងដែលពេញប្រៀបដោយស្នាមស្នេហ៍អតីតប្រាកដដោយកម្តៅឈាមរត់ស្មើនិងកក់ក្តៅល្អជាងថ្ងៃណាៗទាំងអស់។

ត្បិតតែមិនដឹងថាមនុស្សស្រីដែលមានកែវភ្នែកស្រងូតពីម្សិលពិតជាមានស្នេហាជាមួយខ្លួននៅក្នុងអតីតកាលដែលសាបដូចទឹកទន្លេ តែជំនួយការវឌ្ឍនៈពិតជាបានបង្កើតឡើងនូវការតំណាលដ៏អស្ចារ្យមួយសម្រាប់នរៈយើងកាលពីយប់មិញ។

រឿងនិទានស្នេហ៍នៅផ្ទះអនាគតបានធ្វើឱ្យបេះដូងនាយហាក់រស់រានឡើងមកវិញ ចំណែកសម្តីនាងកាលពីម្សិល «ប្រាកដអត់? ថាអត់ស្គាល់ខ្ញុំ?» បណ្តាលចិត្តគេឱ្យស្រងេះស្រងោច។

គេធ្លាក់ទឹកមុខនៅពេលកែវទឹកហៀបនឹងលោមកដល់បបូរមាត់ក្រៀមស្រពោន។ បុរសដាក់គេសផ្ទះចុះ ទាំងរវេភ្នែកគិត.... មិនថាយើងនេះធ្លាប់ស្រលាញ់ឬមិនស្រលាញ់មនុស្សស្រីចម្លែកម្នាក់នោះ ចិត្តយើងបានប៉ះទង្គិចដោយពាក្យសម្តីទាំងឡាយកាលពីម្សិលរបស់នាងពិតណាស់។ ស្នាមថើបដែលនាងផ្តល់មក នៅទីនេះនៅឡើយគឺផ្តិតជាប់ក្នុងចិត្តយើងមិនថាថ្ងៃមិនថាយប់។

បើយើងមិនព្រមជីកកាយរកការពិតចេញមកទេ យើងគ្មានថ្ងៃស្ងប់ជាមួយសម្រែកទាមទារនៃបេះដូងពិកាមួយនេះឡើយ។

ហត្ថានរៈឈោងមកកាន់បង្កាន់ដៃ បណ្តាលទ្រូងនាយនឹកដល់រូបរាងនិងសក់វែងអន្លាយរំផាយតាមកម្លាំងវាយោដែលនាងឈរមើលមកពីលើផ្ទះកាលពីយប់។

គេគ្រវីក្បាលម្នាក់ឯង ហើយថយក្រោយដាក់កែវចុះរួសរាន់ទៅកាន់បន្ទប់ទឹក.....

«ខ្ញុំចង់ជួបមនុស្សម្នាក់ឈ្មោះ ឈុនរាជ!»

គេនិយាយពាក្យនេះពេលដែលបោលឡានមកដល់សាលា។ នៅក្នុងភាគនិទានរបស់វឌ្ឍនៈកាលពីយប់ ជំនួយការជំនិតមិនបាន និយាយរំលងពីឈ្មោះប្រធាននិស្សិតល្បីល្បាញនាយឈុនរាជដែលធ្លាប់ជាបងធម៌របស់ម្ចាស់ស្រីនៃផ្ទះអនាគតនោះឡើយ។ ម្ល៉ោះហើយអ្វីដែលគេអាចធ្វើ ក្រៅពីនៅស្ងៀមរង់ចាំជំនួយការទិញបានសំបុត្របន្ទាន់ជិះពីអាមេរិកមកអាស៊ី គេចាំបាច់ត្រូវធ្វើអ្វីម្យ៉ាង។

តាមរយៈការបង្ហាញរបស់នាយកសាលាគេអាចរកអតីតប្រធាននិស្សិតទាបកន្ទុលបាន។

បុរសល្អិតមហាឆ្លាតវៃកំពុងជជែកស្ការដៃជើងជាមួយក្រុមយុវវ័យជំនាន់ថ្មីនាហាងកាហ្វេកាច់ជ្រុងផ្លូវចូលសាលា។ គេឈប់រៀនយូរហើយ ប៉ុន្តែគេនៅតែមកក្បែរៗនេះព្រោះឪពុកជានាយកនិងស្គាល់ឈ្មោះប្រធាននិស្សិតដ៏ល្បីខាងល្បិចល្បង។

«Lorenzo?»

ឈុនរាជចំហមាត់បន្ទាប់ពីភ្លាត់ចេញនូវឈ្មោះអភិជនសង្ហា។ ទោះពេលនេះគេខូចសម្រស់មួយចំហៀងមុខប៉ុន្តែ គេមិនបានបាត់បង់ភាពឡូយឆាយជាសម្ងាត់ក្នុងភាពស្ងប់ស្ងៀមគ្មានអតីតកាលរបស់គេឡើយ។

ឈុនរាជស្គាល់ខ្លួន រឹងរឹតតែធ្វើឱ្យនាយភ្ញាក់ផ្អើល ប៉ុន្តែរក្សាអាកប្បកិរិយានឹងនជាវិធីដែលLorenzoប្រកាន់ខ្ជាប់រហូតមក។

គេទាញកៅអីអង្គុយទល់មុខ បុរសទាបកន្ទុលស្របពេលអ្នកផ្សេងក្រោកដើរចេញព្រោះឃើញប្រធាននិស្សិតហាក់ស្លុងនឹងវត្តមានបុរសឡូយឆាយ។

«ខ្ញុំចង់ដឹងរឿងទាក់ទងនឹងសន្យា!»

ឈុនរាជ ថ្លោះទឹកមុខ ពីអារម្មណ៍ភ្ញាក់ផ្អើល ហើយចាប់ផ្តើមទទួលអារម្មណ៍ខឹងនិងមានចិត្តចង់ឌឺដង។

គេញញឹមឈឺចាប់ហើយនិយាយដោយងាកមុខចេញដៃលើកពែងកាហ្វផឹកក្អឹកៗ ហាក់មិនស្វាគមន៍បុរសយើង។ ចុងក្រោយគេផ្តើមនិយាយទ្រគោះតែក្នុងសព្ទខ្សោយៗ។

«ឯងក្បត់ប្អូនយើង ទៅការស្រីផ្សេង មានស្អីមកសួរនាំពីវាទៀត?!»

Lorenភ្ញាក់ តែគេនៅតែមើលពីក្រៅហាក់នឹងន។ កែវភ្នែកគេសម្លឹងមុខគូសន្ទនា គឺគេកំពុងមើលឱ្យធ្លុះថាបុរសនេះសម្តែង ឬកន្លងមកគេបានមើលល្ខោនមនុស្សជុំវិញខ្លួនអស់ច្រើនឆ្នាំមកពេលមានឱកាសឮពាក្យពិតនៅថ្ងៃនេះ?

ទោះយ៉ាងណាប្រតិកម្មដំបូងរបស់ឈុនរាជ បានធ្វើឱ្យបេះដូងអ្នកអណ្តែតអណ្តូងរួចទៅហើយ។

«ល្អមើលណាស់ Lorenzo!!» សាជាថ្មីសំឡេងនាង ស្នាមទឹកភ្នែករបស់នាងនិងកម្លាំងដៃរុញរបស់នាងបានរំពើកជាកំស្ទួលរំភើបមួយលេចឡើងក្នុងទ្រូងអភិជនអភ័ព្វ។

គេនិយាយមួយៗទាំងភ្នែកសម្លឹងម្រាមខ្លួនឯងដែលគោះលើពែងតែបៃតង ក្តៅគគុក។

«ខ្ញុំមិនស្គាល់ខ្លួនឯងទេបង! ខ្ញុំគ្រោះថ្នាក់!»

ឈុនរាជលូកដៃកញ្ឆក់ដណ្ដើមយកពែងតែ មកវិញហាក់មិនព្រមស្រន់កំហឹង។ មាត់គេនិយាយស៊កសៀត៖

«បើមិនដឹងខ្លួនផង ម៉េចក៏ហ៊ានរៀបការស្រីផ្សេង?»

«គេប្រាប់ខ្ញុំថា សន្យាជាបងស្រីគេមានជំងឺផ្លូវចិត្តក្រោយពេលវិលចូលផ្ទះ! ខ្ញុំមិនដឹងអ្វីលើសពីហ្នឹងទាំងអស់! រហូតដល់ម្សិលមិញខ្ញុំបានជួបគេ គឺប្អូនស្រីបង!ពេលនេះខ្ញុំមករកបងព្រោះចង់ដឹងរឿងទាំងអស់ មុនពេលគ្រប់យ៉ាងកែលែងបាន!»

ឈុនរាជថមថយអំណាចចិត្តក្រោធ គេហាក់មានសង្ឃឹម ចិត្តអរព្រួចជំនួសប្អូនកម្សត់ ចិត្តមួយទៀតនឹកបារម្ភ តែមាត់នៅរឹង៖

«បើដឹងរឿងហើយឯងហ៊ានដកពាក្យពីស្រីស្អាតពិនណារបស់ឯងនោះដែរ?!»

ប្រុសស្អាតមិនមាត់ តែកែវភ្នែកគេនឹងន។

គេប្រាកដជាគួរឱ្យអាណិតជាងគួរឱ្យខឹង ហេតុអ្វីឱកាសមកដល់មិនប្រឹងស្រវាំកែខៃ ចាប់បែរជានៅពន្យារពេលថា ឱ្យគេញ៉ែតៗដូចមនុស្សស្រី។ ឈុនរាជគិតដូច្នេះបន្ទោសខ្លួន រួច ក៏សម្រួលទឹកមុខហើយនិយាយមួយៗ៖

«តោះ!កុំបាច់និយាយច្រើន យើងដឹកឯងទៅមើលវា!»

គេដើរតត្រុកទៅតាមនាយឈុនរាជដោយទុកចោលឡានខ្លួនឯង។

នៅពេលដែលមនុស្សមាឌទាបកំពុងបង្វេរចង្កូតថយយានចេញពីចិញ្ចើមផ្លូវ គេឆ្លៀតពោលសួរ៖

«ពិនណាដឹងថា សន្យានិងខ្ញុំមានទំនាក់ទំនងអ្វីមែនទេ?!»

«ឯងមិនសួរនាងនោះខ្លួនឯង? បើវាចង់ប្រាប់ វាចាំបាច់ធ្វើបាបចិត្តបងស្រីវាអីចឹងដែរទេ?!»

គេនៅស្ងៀមពេលជនកន្ទុលច្រឡោត។

Lorenzo គឺភាពជាបុរសទន់ភ្លន់នេះហើយធ្វើឱ្យបេះដូងប្រធាននិស្សិតនឹកដល់ប្អូនធម៌ដ៏កម្សត់ដែលធ្លាប់ជួយជីវិតខ្លួន។

គេនិយាយបន្ថែមទាំងដើងជាន់បន្ថែមល្បឿន៖

«សន្យាជាអ្នកជួយជីវិតយើង! ហើយវាជួយជីវិតឯង ថែមទាំងជួយនាងពិនណារបស់ឯង! វាត្រូវគេជំរត់ចេញពីផ្ទះតាំងពីតូចមក ទម្រាំឳពុករកឃើញវិញ ម្ដាយស្លាប់បាត់!វានិងគូដណ្ដឹងឯងជាកូនភ្លោះកើតឆ្នាំនាគដូចគ្នា! កាលឯងនៅមិនទាន់ឈឺ ឯងចូលចិត្តមនុស្សស្រីកើតឆ្នាំរោងណាស់!ឯងមកពីអាមេរិកគឺមករកណាត់ជួបពួកកូនស្រីអ្នកមានៗដែលមានឆ្នាំនាគទាំងអស់មកជួបជាសង្សារ! តែប្អូនយើងវាក្រ រស់នៅជើងភ្នំ មិនទាំងស្គាល់ថាឯងជាអ្នកណាផង!វាជួបឯងពេលឯងធ្លាក់តាមជម្រាលភ្នំ! រឿងក្រោយមកយើងមិនដឹង យើងដឹងតែថានៅក្រោយពិធីសប្បុរសមួយក្នុងភូមិ វាបានដឹងការពិតរបស់ឯង ហើយឯងនៅតែតាមស្រលាញ់វាប្រុងរៀបការជាមួយគ្នា!តែមិនយូរប៉ុន្មាន ឯងក៏ស្រាប់តែបាត់ខ្លួនទៅ!»

Lorenzoនៅស្ងប់ស្ងៀម ក៏ប៉ុន្តែ នាយឈុនរាជដឹងថា ប្រុសម្នាក់នេះកំពុងចង់ដឹងជាខ្លាំង ម្ល៉ោះហើយគេចាប់ផ្ដើមតំណាលប្រាប់បន្ថែម៖

«ចាំស្ដាប់ឱ្យច្បាស់រឿងរបស់ឯងជាមួយសន្យា អាប្អូន!»

**យប់មួយនៅផ្ទះអនាគត**

៥ឆ្នាំមុន......

«កូននាគៗ»

គេស្រែកហៅតែគ្មានសំឡេងតប។ ប្រុសស្អាតទម្លាក់បង្វេចទៅលើគ្រែឫស្សីដែលកាលណោះខ្លួនគ្រេចករើងាកក៏មិនចង់បាន ហើយចាំបានថាខ្លួនមិនចង់សូម្បីស្នាក់នៅទីនេះបន្ថែមមួយវេលាណា។

ហេតុអ្វីពេលនេះអន្ទះសាចង់វិលមកវិញ។

«អ្ហូយទីបំផុតបងឯងមកចំពេលល្អហ្មង!»

សំឡេងនាងនៅមាត់ទ្វារធ្វើឱ្យនរៈបែរខ្លួនទៅដោយស្វ័យប្រវត្តិ។

នារីនេះរត់មកទាំងញើសកក្លាក់ហើយឱបផ្កាព្រៃមួយសំណុំត្រកងក្នុងដៃ។

«មកពីណា?»

គេនិយាយខ្លីៗ ព្រោះមាត់រវល់ញញឹមស្វាគមន៍ការមកដល់របស់នាង។ សរសៃសក់វែងអន្លាយរបស់សន្យារសាត់ប៉ើងៗតិចៗ តាមកម្លាំងខ្យល់ជាយព្រៃ បន្ថែមសម្រស់នាងជាមួយផ្កាពណ៌ស្វាយមួយបាច់ធំក្នុងហត្ថា ញ៉ាំងឱ្យបុរសនេះចង់គូរគំនូររូបនាងរក្សាទុកក្នុងបេះដូងជារៀងរហូត។

«ឮបងសួរអត់ មកពីណា?»

នាងដាក់ផ្កាទៅម្ខាងហើយស្ទុះមកទាញបង្វិលរាងកាយនាយពិនិត្យមុនក្រោយ។

«ធ្វើអីនៀក?»

នេះជាលើកដំបូងក្នុងជីវិតអភិជន Loren ដែលមានអ្នកណាម្នាក់មកបង្វិលកាយគេពិនិត្យគ្រវាត់គ្រវែង។ តាមថាគេនឹងខឹងហើយធ្វើឫកដូចចុះមកពីលើមេឃ តែថ្ងៃនេះគេញញឹមតាមដាននាងហើយក៏មិនជំទាស់នឹងសកម្មភាពស្លន់ស្លោរបស់នាង។

«ខ្ញុំត្រូវការមនុស្សម្នាក់ បន្លំធ្វើជា Lorenzo»

បុរសគាំងចលនា គេនៅធ្មឹង ពេលឮពាក្យនាង។ គេខំពិនិត្យមើលតើនាងនិយាយពិតឬមួយនាងធ្វើពុត។ នាងនៅតែបង្វិលកាយគេហើយពោលបង្អាប់៖

«បងឯងមើលយ៉ាងណាក៏នៅតែក្រៗ ធ្វើ Lorenzo គ្មានអ្នកណាគេជឿដឹង?»

នាងនិយាយសរសើរឬបង្អាប់? គេគិតហើយជ្រួញចិញ្ចើមមួម៉ៅ។ គេសម្លឹងថ្ងាសនាងដែលឈ្លោកទាបកញ្ច្រិចនៅក្រោមទ្រូង ហើយឆ្លេឆ្លាពិនិត្យខ្លួននាយចុះឡើងមិនដាច់ស្រេច។

Loren គំហកតិចៗ៖

«និយាយរឿងស្អីនៀក?»

ស្រីតូចងើបមុខមកវិញ ហាក់មិនអើពើនឹងកំហឹងក្នុងភ្នែកនាយ នាងនិយាយពន្យល់ប្រញិបប្រញាប់៖

«នៅភូមិមានពិធីអង្គាសលុយសង់សាលានិងបុកអណ្ដូង! ពួកថៅកែៗចុះមកពីខេត្តច្រើនណាស់! មេភូមិប្រាប់ថា ពួកនោះភាគច្រើនធ្វើបុណ្យតាមគ្នា និយាយឱ្យស្រួលស្ដាប់គឺធ្វើបុណ្យយកមុខ! កាលណាមានអ្នកមានមកពីភ្នំពេញចូលរួម ពួកគេកាន់តែខំបរិច្ចាគ ឥឡូវនេះវ៉ណ្ដែកហើយ ខ្ញុំកុហកគេថាបងធម៌ខ្ញុំស្គាល់ Lorenzo សន្យាថា Lorenzo នឹងមកចូលរួមនៅទីនោះ! មានថៅកែសិប្បកម្មថៅកែមាសថៅកែដី ថៅកែស្វាយ ថៅកែស្រាមកចុះឈ្មោះរាប់រយនាក់! ពួកគេចង់ថតជាមួយ Lorenzo ពេលនេះបងឈុនរាជខលមកថារក Lorenzo មិនឃើញ! ចប់ហើយខ្ញុំ!»

«ស្រលះទៅ ក្មេងប៉ិនកុហក!»

គេថាឱ្យទាំងមុខស្មើ។ loren តាំងពីដើមមកស្អប់បំផុត អ្នកណាដែលប្រើឈ្មោះនាយយកលាភយកមុខ។ ពេលនេះស្អប់ណាស់ជួបណាស់។

សន្យាឃើញនាយថាឱ្យហើយធ្វើមុខស្មើចែសទៀត នាងក៏ធ្វើមុខចង់យំសម្លឹងនាយបកវិញភ្លឹះៗ។ ចិត្តស្នេហាបានគ្របដណ្ដប់ត្រជាក់ល្ហើមមកលើបេះដូងបុរស។ គេផ្ដើមស្រាយទឹកមុខសន្សឹមៗហើយញញឹមសួរតិចៗ៖

«ចុះបើគេដឹងការពិត មានរឿងអីកើតឡើង?»

«អ្នកភូមិនឹងបណ្ដេញលែងឱ្យធ្វើពិធី! ខូចឈ្មោះ ហើយថ្ងៃក្រោយកុំសង្ឃឹមបានប្រមូលលុយបរិច្ចាគអីទៀត!»

«សមមុខ!»

គេរអ៊ូតិចៗ តែនាងលបស្ដាប់ឮហើយវាយនាយផាច់ៗ។

«ខ្ញុំមិនដឹង! បងឯងត្រូវក្លែងធ្វើជាគេ ដើរតួឱ្យបានល្អបំផុត!»

គេនៅស្ងៀមដៀងភ្នែកសម្លឹងនាង ជាពន្លឺភ្នែកពេញដោយសេចក្ដីកក់ក្ដៅ និងភាពឈឺឆ្អាលដែលមានតែមនុស្សស្រលាញ់គ្នាទេ គេប្រើវាចេញមកបាន។

ពីដំបូងឡើយ ចិត្តអាណិកជនគឺចង់ចេញពីទីនេះឱ្យកាន់តែឆាប់ តាមដែលអាចធ្វើទៅបាន ហើយនាំនារីតូចនេះទៅជាមួយ។ ពីតាមផ្លូវមកកាលណាគេប្រាថ្នានិយាយការពិតប្រាប់ដល់នាង ហើយនាំនាងទៅ តែពេលនេះ នាងមើលទៅហាក់មិនចង់ឮអ្វី ក្រៅតែពីតួអង្គ lorenzo ក្លែងក្លាយនោះទេ។

«មិញពីណាថាបងមើលទៅក្ររហាម! ធ្វើអីក៏មិនសមហើយមករកបងធ្វើអី?»

«ចាំខ្ញុំបង្រៀនបងឯងធ្វើឫកឱ្យសមអ្នកមាន!»

គេចងចិញ្ចើម។ តើគួរសើច ឬយំនៀក?

គេគិតផងត្រូវនាងអូសទីណាត់ទីណែងឱ្យឈរកណ្ដាលផ្ទះ។ នាងចាប់ផ្ដើមនិយាយ៖

«តោះឧបមាថា បងឯងកំពុងពាក់អាវធំហើយ ហើយមនុស្សជាច្រើនសងខាងផ្លូវចាំស្វាគមន៍ បងឯង! បងឯងជាអ្នកមានលុយបរិច្ចាគច្រើនជាងគេក្នុងកម្មវិធី ហើយបងឯងជាអ្នកមានដែលគ្រប់គ្នាដណ្ដើមចង់ Selfie ដាក់ Facebook! តោះឥឡូវនេះទ្វារនៅខាងណោះ គ្រប់គ្នានៅចំហៀងនេះមើលមកបងឯង! ពេលមេក្រូប្រកាសថាលោក Lorenzo មកដល់ហើយ បងឯងដើរចូលមកឱ្យសង្ហា! តោះ! ដើរមកៗ»

នាងបក់ដៃហៅភ្លាមៗធ្វើឱ្យបុរសរង៉ីរង៉េ។

គេដើរមួយៗ ចូលមកតែនាងធ្វើមុខមិនពេញចិត្តសោះឡើយ។ នាងរអ៊ូ៖

«បងឯងមិនដែលពាក់អាវធំមិនដែល ចូលពិធីធំ ដើរឆ្គងអ៊ីចឹងហ្មង! នៀកៗចាំខ្ញុំធ្វើឱ្យមើល! Lorenzoគេដើរអ៊ីចេះ!»

បុរសឈប់ស្ងៀមហើយដៀងភ្នែកមកសម្លឹងនាងច្រមក់។

នាងបន្ទោសចច្រែត៖

«បងឯងឈប់ធ្វើអី? ប្រឹងរៀនឡើងត្រូវមានការងារច្រើនណាស់ត្រូវទៅ រកជួលអាវធំមកពាក់ទៀតណំា! ហើយសក់នៀក សក់មើលទៅមិនសមអ្នកមានសោះត្រូវកាត់ចេញ!»

«អ្ហះ? កាត់សក់?»

ព្រលឹមស្រាងៗ កូននាគនៅក្នុងភូមិជាមួយអ្នករៀបចំកម្មវិធីរបស់នាង។ នាងស្លៀកពាក់ខ្មែរអាវប៉ាក់សំពត់ហូលស្អាតដូចទេវតាតែ នាងអន្ទះអន្ទែងរង់ចាំមើលតែផ្លូវបុរស Lorenzo របស់នាង។

«សន្យា! អត់បែកការណ៍ទេហ្អីក្មួយ?»

ពូនាងសួរទាំងភ្នែកកញ្ជឹងក ព្រោះដង្ហៅៗបើកឡានទំនើប មកបន្តបន្ទាប់គ្នា ព្រោះគេស្ទប់ស្ទែងតារាសប្បុរសនៅភ្នំពេញដែលធ្លាប់ឮតែឈ្មោះ កម្រមានអ្នកមានបានឃើញមុខ។

«ពូកុំស្លន់ប្រយ័ត្នគេដឹង! អត់អីទេ! គេនោះសង្ហាដែរតើ! ខ្ញុំបង្ហាត់គេមួយយប់ហើយ! សង្ឃឹមថាគ្រប់យ៉ាងដំណើរការដោយរលូន!»

«គេនៅឯណា ថ្មើរណាបានមក!?»

«អត់អីទេពូអាចយឺតតិចតួច ប៉ុន្តែគេចេញតាំងពីល្ងាចមិញ ទៅរកជួលអាវនិងកាត់សក់!»

រថយន្តទំនើបខ្សែវែងដែលអ្នកស្រុកនេះមិនដែលទិញជិះបង្ហាញខ្លួនក្បែររោងបុណ្យ។ ពួកគេនាំគ្នាដកកមើល ព្រោះឡានទាំងនេះមានតែពួកមហាសេដ្ឋីខ្មែរដែលមានលទ្ធភាពទិញជិះ។

«Lorenzo មកដល់ហើយ!»

ម្នាក់ៗខ្សឹបខ្សៀវគ្នាលាន់រំពង ហើយគ្រប់គ្នាក្រោកមកក្បែរផ្លូវចូលដើម្បីបានរលាក់ដៃតួសប្បុរសដ៏ល្បីរន្ទឺ។ កាមេរ៉ាគ្រប់គ្នាក៏បានត្រៀមថត ធ្វើឱ្យពូនាងដែលយកនាងមកចៃចិញ្ចឹមតាំងពីតូចក្រូចឆ្មារពេលនេះចំហមាត់គាំង។

ប្រុសស្អាត Lorenzo មិនបានជួលអាវធំអ្វីពាក់ដូចនាងបញ្ជាកាលពីយប់ទេ ប៉ុន្តែគេចេញពីក្នុងជួររថយន្តខ្មៅស្ទិលបន្តគ្នា៦គ្រឿង ហើយដើរមកក្នុងចំណោមអ្នកហែហមមានទាំងជំនួយការវឌ្ឍនៈផងធ្វើឱ្យគេមានរូបភាពជារាជបុត្រ Lorenzo ពិតៗដូចដែលអ្នកស្រុកធ្លាប់ល្បី។

នាងងាកមកមើលបុរសនេះ ហើយធ្វើភ្នែកភាំងៗចំពោះស្នាមញញឹមស្រស់របស់នាយ។ អ្នកស្រុកដណ្ដើមគ្នាលោក់ដៃ និងថតរូបជាមួយគេ។ ដង្ហៅទាំងឡាយញញឹមបិទមាត់មិនជិតពេលគេដើរមកដល់ ហើយចុងក្រោយគេក៏ងាកមកឃើញនាង.....

កូននាគដែលស្លៀកពាក់សុភាពរាបសាគួរឱ្យស្រលាញ់ កំពុងចំហមាត់ចងចិញ្ចើមសម្លឹងដំណើរដូចរាជសីនៃប្រុសស្អាត ព្រោះ Lorenzo បានបំបែរគោលដៅ ដើរមួយៗមករកនាង។

អង្គរក្សទាំងឡាយរួមទាំងជំនួយការវឌ្ឍនៈផងថយទៅក្រោយ ទុកឱកាសនេះឱ្យចៅហ្វាយចូលទៅសាងភាពឯកជនជាមួយកូននាគតូច....

នាងសម្លឹងនាយដោយកែវភ្នែកស្រទន់។ គេពិតជាសង្ហាជារាជបុត្រក្នុងរឿងបុរាណដែលនាងតែងតែស្រមៃប្រឌិតហើយនិទានបង្អួតក្មេងៗនៅផ្ទះអនាគត។

ដំណើរនាយពិតជាហ៊ឺហារហួតបេះដូងសឹងភ្លេចដកដង្ហើមបាន។

ចំហាយនៃចរន្តរត់រកគ្នារវាងភេទផ្ទុយទាំងទ្វេមានអានុភាពអាចបណ្ដាលឱ្យបេះដូងស្រីតូចចេញដង្ហើមកាន់តែក្ដៅឡើងៗ។

គេមកដល់ហើយ គឺមកកៀកប្រមាណជាពីរចំអាមពីនាង ហើយភ្នែកនាងត្រូវទើរត្រឹមតែដើមទ្រូងគេព្រោះចាញ់កម្ពស់។

នាងងើបមុខឡើងមើលគេមិនរួច ព្រោះអៀនមហាអៀន។ ឃើញនាងចាញ់ប្រាបភាពជាបុរសនិងមន្តស្នេហ៍របស់គេ Loren នៅស្ងៀមសម្លឹងនាងទុកឱ្យកាមេរ៉ាទាំងឡាយបាញ់តាមត្រូវការ។

ស្រីស្អាតស្រវារកវិធីបំបែកអារម្មណ៍អៀនហើយបន្ទោសតិចៗ៖

«មនុស្សបងឯង ប្រាប់ឱ្យធ្វើអ៊ីចេះទៅធ្វើអ៊ីចុះ! ឱ្យជួលអាវធំពាក់ បងឯងជួលឡានមកម្ដង៦គ្រឿង! ខ្ញុំបានស្អីទៅបង់គេ? ហើយអស់ប៉ុន្មានជួលប៉ុណ្ណឹង? ខ្ញុំបានលុយឯណាឱ្យថ្លៃឡានគេនៀក»

នាងងើបមុខមកជាមួយកង្វល់ តែនាងត្រូវទើរព្រោះគេសម្លឹងនាងយ៉ាងស្រទន់។ សន្យានៅគាំងកណ្តាលសមុទ្រស្នេហាដែលល្ងឹងល្ងើយដូចគ្មានអ្នកណានៅទីនេះក្រៅតែពីនាងហើយនឹងគេ។ សូរសព្ទមេក្រូលាន់មកកោកៗផ្តាច់សង្វាក់ដង្ហើមក្តៅឧណ្ហៗរបស់នាង៖

«សរុបប្រាក់បរិច្ចាគគឺបាន សាលាបួនខ្នងនិងអណ្តូង២២៣! ក្នុងនោះលោក Lorenzo តែឯងបានជួយ១០០ អណ្តូងនិងសាលាផ្ទះអនាគតចំនួនពីរខ្នង! លុយសុទ្ធទាំងអស់នៅទីនេះ»

«ហើយបងឯងបានលុយពីណាមក? បងឯងធ្វើម៉េចបានជា ធ្វើដល់ថ្នាក់ហ្នឹង! ឪខ្ញុំហ្មែន?»